00172879

**Declassified to Public**
**06 September 2012**

ការចារ/ហ D 58/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 03 / 2008
ម៉ោង (Time/Heure): 12 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សូមជម្រាបមក

# លោកប្រធានសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

**កម្មវត្ថុ ៖** ការសុំពិនិត្យ និង ថតចម្លងឯកសារនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

ផ្អែកតាមកម្មវត្ថុខាងលើ យើងសូមជូនដំណឹងដល់លោកប្រធានអោយជ្រាបថា នៅក្នុងដំណើរការស៊ើបសួររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានតម្រូវការចាំបាច់នៅក្នុងការពិនិត្យ និង ថតចម្លងឯកសារមួយចំនួនដែលមាននៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។
ដើម្បីអនុវត្តការងារនេះអោយមានភាពរលូន យើង បានចាត់តាំងអ្នកស៊ើបអង្កេតនៃការិយាល័យរបស់យើង អោយអនុវត្តនូវដីកាចាត់អោយស៊ើបសួរជំនួសចុះថ្ងៃទី២ ខែមករា ឆ្នាំ ២០០៨ ដែលមានភ្ជាប់មកជាមួយ ដើម្បីបំពេញកិច្ចការនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ យើង សូមអោយលោកប្រធានសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងធ្វើការសហការជាមួយ និង ជួយសម្រួលដល់អ្នកស៊ើបអង្កេតខាងលើក្នុងការបំពេញបេសកកម្មដែលបានប្រគល់ជូនដោយដីកាចាត់អោយស៊ើបសួរជំនួសនេះ។

សូមលោកប្រធានទទួលនូវការគោរពរាប់អានអំពីយើង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ ២០០៨

សហចៅក្រមស៊ើបអង្កេត

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

MARCEL Lemonde          យូ ប៊ុនឡេង

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 21 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA KO??

សូមជូនភ្ជាប់ ៖ ដីកាចាត់អោយស៊ើបសួរជំនួស

ចម្លងជូន៖ ការិយាល័យរដ្ឋបាលនៃអ.វ.ត.ក